ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ: ១៧៩ប្រ

ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤

សាលដីកា

លេខ: ១៦៦

ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៤

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៤

ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ខិម** | **ធុន្នី** | ជាប្រធាន |
| ២-លោក | ជីវ | កេង | ជាចៅក្រម |
| ៣-លោក | យស់ | សូខឿន | ជាចៅក្រមរបាយការណ៍ |
| ៤-លោក | ប្រាក់ | គីមសាន | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុនីចរិយា | ជាចៅក្រម |
| | ក្រឡាបញ្ជី | | |
| អ្នកស្រី | **នួន** | **ចន្ថា** | |
| | តំណាងមហាអយ្យការ | | |
| លោក | **ឈួន** | **ចាន់ថា** | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៩៦ "ឈ" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២២២ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រវាង:

ដើមចោទឈ្មោះ **អ៊ុង ម៉េងស៊ួន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅផ្ទះលេខ៩៤ ផ្លូវ១៦៤ សង្កាត់អូរឬស្សីទី៣ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ។

មានមេធាវីលោក ជីវ សុងហាក់ ។

ចុងចំលើយឈ្មោះ **យាក ឡុងទាង** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៦៦ឆ្នាំ ជនជាតិតៃវ៉ាន់ ទីលំនៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។

ផ្ទេរសិទ្ធិឱ្យលោក សាយ ពិសិដ្ឋ ។

មានមេធាវីលោក សែម ចិន្តា ។

**កម្មវត្ថុបណ្ដឹង** : ប្ដឹងឃាត់ការលក់ផលិតផលចាហួយតៃវ៉ាន់គ្រប់ប្រភេទ ផលិតដោយក្រុមហ៊ុន TAIWAN FOOD PRODUCT ENTERPRISE CO.LTD ឱ្យទៅអ្នកផ្សេង ក្រៅពីលោក អ៊ីង ម៉េងស្រ៊ុន .

បានឃើញបណ្ដឹងសាទុក្ខលេខ១៧១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះជីវ សុងហាក់ ជាមេធាវីការពារឱ្យឈ្មោះអ៊ីង ម៉េងស្រ៊ុន ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៦"ឃ" ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៧៩ប្រ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១៦-៣-២០០៤ របស់លោកជីវ សុងហាក់ ប្ដឹងសុំដូចមានក្នុងកម្មវត្ថុខាងលើ ដោយសំអាងហេតុថា :ក្រុមហ៊ុនបានចុះកិច្ចសន្យាប្រគល់សិទ្ធិលក់ផលិតផលផ្ដាច់មុខនូវផលិតផលចាហួយរបស់ខ្លួនគ្រប់ប្រភេទតាមកិច្ចសន្យាចុះថ្ងៃទី០១-៤-២០០០ តែរហូតមកដល់ដើមខែមិនា ឆ្នាំ២០០៤នេះ ក្រុមហ៊ុននេះបានបញ្ឈប់ការលក់ផលិតផលឱ្យលោកអ៊ីង ម៉េងស្រ៊ុន ដោយគ្មានមូលហេតុ ហើយបើកលក់ជាសាធារណៈឱ្យអ្នកផ្សេងទៀត ដោយគ្មានគោរពកិច្ចសន្យា និងគ្មានការយល់ព្រមពីលោក អ៊ីង ម៉េងស្រ៊ុន ឡើយ ។

បានឃើញដីកាសំរេចតាមពាក្យសុំលេខ ១៣"ង" ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងសុំដីកាសំរេចតាមពាក្យសុំរបស់ឈ្មោះជីវ សុងហាក់ មេធាវីតំណាងរបស់ឈ្មោះអ៊ីង ម៉េងស្រ៊ុន ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៤ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ឈ្មោះជីវ សុងហាក់ មេធាវីតំណាងស្របច្បាប់របស់ឈ្មោះអ៊ីង ម៉េងស្រ៊ុន តាមលិខិតចុះថ្ងៃទី១៥-៣-២០០៤ ។

៣-ហាមឃាត់ជាបណ្ដោះអាសន្ន ក្រុមហ៊ុនតៃវ៉ាន់ ហ្វូតប្រូដាក់អ៊ិនធើប្រាយ ខូអិលធីឌី មិនឱ្យលក់ផលិតផលចាហួយ តៃវ៉ាន់គ្រប់ប្រភេទទៅឱ្យអ្នកផ្សេង ក្រៅពីលោកអ៊ីង ម៉េងស្រ៊ុន ចាប់ពីថ្ងៃនេះតទៅ រង់ចាំតុលាការសំរេចដល់រឿងអង្គសេចក្ដីជាស្ថាពរ ។

៤-បង្គាប់ឱ្យឈ្មោះជីវ សុងហាក់ បង់ប្រាក់ប្រដាប់ក្ដីគឺ: ពន្ធចុះបញ្ជីក្ដី៩០០៛ និងពន្ធហ្វឹង ៩០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ សរុប ២០០០រៀល ។

៥-ដីកាសំរេចនេះ ធ្វើនៅចំពោះមុខអ្នកប្ដឹងសុំ កំបាំងមុខភាគីចុងចម្លើយ សំរេចបើកផ្លូវប្ដឹងទាស់១៥ថ្ងៃ គតិចាប់ពីបានទទួលដំណឹងពីដីកាសំរេចនេះតទៅ និងមានអានុភាពអនុវត្តភ្លាមៗ ។

បានឃើញបណ្ដឹងទាស់លេខ១០០៩/៩១-៩១១ ចុះថ្ងៃទី២៣-៣-២០០៤ របស់ឈ្មោះ ចង លីវ

ជាតំណាងឱ្យក្រុមហ៊ុនតៃវ៉ាន់ហ្វូតប្រូដាក់អ៊ិនធើប្រាយខូអិលធីឌី ប្តឹងមិនសុខចិត្តនឹងដីកាសំរេចកិច្ចការប្រញាប់ លេខ ១៣"ង" ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ ០៧ប្រ(ង) ចុះថ្ងៃទី០១-៤-២០០៤ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់របស់ឈ្មោះ ចង លីវ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០០៤ និងសំណូមពររបស់លោក ផាត់ សុផល ជាមេធាវីតំណាងនាពេលជំនុំជំរះកិច្ចការប្រញាប់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-ទទួលស្គាល់លោក ផាត់ សុផល ជាមេធាវីតំណាងស្របច្បាប់របស់ឈ្មោះចង លីវ តាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៨-៣-២០០៤ ។

៣-ទទួលស្គាល់លោក ជីវ សុងហាក់ ជាមេធាវីតំណាងស្របច្បាប់របស់ឈ្មោះអ៊ឹង ម៉េងស្រ៊ុន តាមលិខិតប្រគល់សិទ្ធិចុះថ្ងៃទី១៥-៣-២០០៤ ។

៤-តំកល់ដីកាសំរេចតាមពាក្យសុំលេខ១៣"ង" ចុះថ្ងៃទី១៦-៣-២០០៤ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ចាប់ពីថ្ងៃនេះតទៅ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៤.០០០៛ តាមច្បាប់ ដែលលោកផាត់ សុផល បានបង់រួច។

៦-ដីកាសំរេចនេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៧-ដីកាសំរេចនេះ ជំនុំជំរះចំពោះមុខគូភាគី សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៩"ង" ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ របស់ឈ្មោះយាក ឡុងខាង ប្តឹងមិនសុខចិត្តនឹងដីកាសំរេចកិច្ចការប្រញាប់លេខ០៧ប្រ"ង" ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុច ដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៥៦"ឈ" ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៨-០៤-២០០៤ របស់ឈ្មោះ យាក ឡុងខាង (YEH LUNG KANG) ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធដីកាសំរេចកិច្ចការប្រញាប់លេខ ០៧ប្រ"ង" ចុះថ្ងៃទី០១-០៤-២០០៤ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-អនុញ្ញាតឱ្យក្រុមហ៊ុន TAIWAN FOOD PRODUCT ENTERPRISE Co..,LTD លក់

ផលិតផលចាហួយតៃវ៉ាន់របស់ខ្លួនឱ្យទៅលោកអ៊ឹង ម៉េងស្រ៊ុន និងអតិថិជនផ្សេងៗទៀត ជាបណ្តឹងអាសន្នសិនទំរាំតុលាការសំរេចរឿងអង្គសេចក្តីចប់ជាស្ថាពរ ។

៤-រឹបយកប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ទុករួចហើយ គឺ ពន្ធចុះបញ្ជីក្តី និងពន្ធភ្លើង ២.៥០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងអាជ្ញាធរតុលាការ ៥.០០០៛ ។

៥-សាលដីកានេះ មានអានុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

៦-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៧១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះជីវ សុងហាក់ ជាមេធាវីការពារឱ្យឈ្មោះអ៊ឹង ម៉េងស្រ៊ុន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥៦"ឃ" ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះអ៊ឹង ម៉េងស្រ៊ុន ។

បានឃើញសារណាតបចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះយ៉ាក ឡុងខាង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :បណ្តឹងសាទុក្ខរបស់មេធាវីតំណាងឱ្យដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

សាលដីការដ្ឋប្បវេណីលេខ ៥៦"ឃ" ចុះថ្ងៃទី១៤-០៥-២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់និងគតិច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់។

បានស្តាប់ចម្លើយរបស់ឈ្មោះ អ៊ឹង ម៉េងស្រ៊ុន នាពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលនេះ មកពីសាលាឧទ្ធរណ៍ពុំបានពិចារណាលើកិច្ចសន្យារបស់ខ្លួនឡើយ ។ ខ្លួនប្តឹងមកនេះ គឺសុំប្តឹងរំលាយកិច្ចសន្យា និងប្តឹងសុំលក់ផលិតផលចាហួយតៃវ៉ាន់ផ្ទាច់មុខតែម្តង ព្រោះកិច្ចសន្យានៅមានសុពលភាពនៅឡើយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសាយ ពិសិដ្ឋ តំណាងឱ្យចុងចម្លើយ នាពេលសវនាការថា : លោកអ៊ឹង ម៉េងស្រ៊ុន ប្តឹងពីក្រុមហ៊ុនខ្លួនអំពីអង្គសេចក្តីនេះ លោកអ៊ឹងម៉េងស្រ៊ុន មិនបានទៅទិញផលិតផលចាហួយតៃវ៉ាន់ដូចរាល់ដងទេ ធ្វើឱ្យរាំងស្ទះដំណើរការផលិត មិនបានលក់ផលិតផល គ្មានប្រាក់បង្វិលដើមទុន គ្មានប្រាក់ចំណាយលើបុគ្គលិកកម្មករ ។ ខ្លួនសុំដីកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការតាមច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកជីវ សុងហាក់ ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងនាពេលសវនាការថា : បានជាកូនក្តីខ្លួនប្តឹងរំលាយកិច្ចសន្យាចុះថ្ងៃទី០១-៤-២០០០ តែសុំលក់ផលិតផលឱ្យមកកូនក្តីខ្លួន ព្រោះប្រការ៣នៃកិច្ចសន្យាបានចែងយ៉ាងច្បាស់ ។ កិច្ចសន្យានេះក៏មិនបានកំណត់អំពីបរិមាណ

នៃផលិតផលដែរ ។ គោលការណ៍នៃរំលាយកិច្ចសន្យាមានដូចតទៅ : ១-ភាគីទាំងពីរព្រមព្រៀងគ្នា ២-ភាគីម្ខាងបានបំពេញកាតព្វកិច្ចចប់សព្វគ្រប់. ៣-ការរំលាយកិច្ចសន្យាតាមអំណាចសាលក្រមស្ថាពររបស់តុលាការ ។ ដូច្នេះកូនក្តីរបស់ខ្លួននៅតែសំណូមពរលក់ផលិតផលឱ្យខ្លួនដដែល រហូតដល់រឿងអង្គសេចក្តីចប់ជាស្ថាពរ ។ ព្រោះកូនក្តីខ្លួនបានចំណាយទុនយ៉ាងច្រើនដើម្បីស្វែងរកទីផ្សារ រឿងនេះកើតឡើងដោយអ្នកទទួលខុសត្រូវថ្មីរបស់ក្រុមហ៊ុនមិនបានពិនិត្យលើកិច្ចសន្យាពីមុនមក ។ ហើយដីកាសំរេចកិច្ចការប្រញាប់របស់តុលាការក្រុងភ្នំពេញ មិនបានធ្វើឱ្យខូចខាតផលប្រយោជន៍របស់ក្រុមហ៊ុនឡើយ ។ ខ្លួនសុំតំកល់ដីកាសំរេចកិច្ចការប្រញាប់របស់តុលាការក្រុងភ្នំពេញទុកជាបានការនិងសូមបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក សែម ចិន្តា មេធាវីការពារឱ្យចុងចម្លើយ បានលើកឡើងនាងពេលសវនាការថា :លោកអ៊ឹង ម៉េងស្រ៊ុន គាត់ប្តឹងសុំរំលាយកិច្ចសន្យាចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០០ និងប្តឹងសុំដីកាចារលើពាក្យសុំ និងដីកាកិច្ចការប្រញាប់សុំហាមឃាត់មិនឱ្យក្រុមហ៊ុនកូនក្តីខ្លួនលក់ផលិតផលចាហួយតៃវ៉ាន់ទៅឱ្យអ្នកដទៃផ្សេងៗទេ គឺលក់ឱ្យតែគាត់ម្នាក់នោះ ធ្វើឱ្យក្រុមហ៊ុនកូនក្តីខ្លួនមានការរាំងស្ទះដល់ដំណើរការអាជីវកម្មយ៉ាងធ្ងន់ធ្ងរ ដោយហេតុថា លោកអ៊ឹង ម៉េងស្រ៊ុន ទិញផលិតផលចាហួយតៃវ៉ាន់ក្នុងបរិមាណដ៏តិចតួច និងមិនបានទៅទិញផលិតផលពីក្រុមហ៊ុនកូនក្តីខ្លួនតាំងពីពេលបណ្តឹងអង្គសេចក្តីរហូតមកដល់ពេលនេះវាធ្វើឱ្យក្រុមហ៊ុនកូនក្តីខ្លួនក្ស័យធន គ្មានប្រាក់ចំណូលសំរាប់បង្វិលទុន គ្មានប្រាក់សំរាប់ចំណាយលើបុគ្គលិក និងកម្មករឡើយ ។ ហើយកូនក្តីខ្លួនបានជូនដំណឹងទៅដើមចោទ ឱ្យមកទទួលយកផលិតផលប៉ុន្តែដើមចោទពុំបានមកទំនាក់ទំនងជាមួយក្រុមហ៊ុនទេ ។ខ្លួនសុំសំណូមពរសុំឱ្យតុលាការកំពូល មេត្តាសំរេចតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមច្បាប់ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ របស់លោកជីវ សុងហាក់ មេធាវីដើមចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍អនុញ្ញាតឱ្យក្រុមហ៊ុន TAIWAN FOOD PRODUCT ENTERPRISE CO.LTDលក់ផលិតផលចាហួយតៃវ៉ាន់របស់ក្រុមហ៊ុនឱ្យអតិថិជនផ្សេងៗទៀតជាមួយនឹងលោកអ៊ឹង ម៉េងស្រ៊ុនដែរនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះគូភាគីបានធ្វើកិច្ចសន្យាចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០០ ព្រមព្រៀងប្រគល់សិទ្ធិលក់ផ្តាច់មុខនូវផលិតផលចាហួយតៃវ៉ាន់ឱ្យដើមចោទ ដើម្បីលក់ចែកចាយនៅលើទីផ្សារ

ទូទាំងប្រទេស ហើយក្នុងកិច្ចសន្យាបានបញ្ជាក់ច្បាស់ថា ចុងចម្លើយមិនអាចលក់ផលិតផលចាហួយទៅឱ្យឈ្មួញ ដទៃដោយគ្មានការអនុញ្ញាតពីដើមចោទឡើយ ។ កិច្ចសន្យានេះ នៅមានសុពលភាពនៅឡើយដែរ។

- យល់ឃើញថា នៅពេលសវនាការនេះចុងចម្លើយនិងមេធាវីបានលើកឡើងថា ខ្លួនបានជូនដំណឹងឱ្យដើមចោទមកទទួលយកផលិតផលទៅលក់ហើយ ប៉ុន្តែដើមចោទពុំមកទំនាក់ទំនងជាមួយក្រុមហ៊ុនទេ បើឱ្យលក់ផ្តាច់មុខឱ្យដើមចោទអាចនឹងធ្វើឱ្យក្រុមខ្លួនក្ស័យធននោះ តុលាការកំពូលគប្បីពិចារណាដល់លក្ខខ័ណ្ឌសមស្របដែលដើមចោទត្រូវទទួលខុសត្រូវ ។

- យល់ឃើញថា ការដែលមេធាវីចុងចម្លើយលើកឡើងថា ដើមចោទប្តឹងជារឿងអង្គសេចក្តីសុំរំលាយកិច្ចសន្យា ប៉ុន្តែបែរជាមកប្តឹងសុំកិច្ចការប្រញាប់មិនឱ្យក្រុមហ៊ុនលក់ផលិតផលឱ្យអ្នកផ្សេងនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះកិច្ចសន្យាចុះថ្ងៃទី១-៤-២០០០ មិនទាន់ត្រូវបានរំលាយទេ ។ ដូច្នេះតាមគោលការណ៍កិច្ចការប្រញាប់ តុលាការត្រូវរក្សាស្ថានភាពដើមមុនពេលមានទំនាស់សិន ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៥៦ "ឈ" ចុះថ្ងៃទី១៤-៥-២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ខ្លះ ត្រូវខ្លះ ប៉ុន្តែដើម្បីឱ្យងាយស្រួលក្នុងការអនុវត្ត គប្បីទុកជាមោឃៈទាំងមូល និងសំរេចជាថ្មី ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខតុក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ១៧១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ របស់លោកជីវ សុងហាក់ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ខ្លះ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥៦"ឈ"ចុះថ្ងៃទី១៤-៥-២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូលដោយឥតបង្វិល ។

៣-ហាមឃាត់ក្រុមហ៊ុន TAIWAN FOOD PRODUCTION ENTERPRISE CO.LTD តំណាងដោយលោកយាក ឡុងខាង មិនឱ្យលក់ផលិតផលចាហួយតៅវ៉ាន់គ្រប់ប្រភេទឱ្យទៅអ្នកដទៃ ក្រៅពីលោកអ៊ឹង ម៉េងស្រ៊ុន ជាបណ្តោះអាសន្នរង់ចាំតុលាការសំរេចដល់អង្គសេចក្តី ។ បើលោកអ៊ឹង ម៉េងស្រ៊ុន មិនព្រមទៅទទួលយកទំនិញនេះទៅលក់និងទូទាត់សងប្រាក់តាមទំលាប់ពីមុនមកទេ លោកត្រូវទទួលខុសត្រូវរាល់ការខាតបង់ ផលប្រយោជន៏ផ្សេងៗរបស់ក្រុមហ៊ុនTAIWAN FOOD PRODUCTION ENTERPRISECO.LTD ។

៤-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១៧៩ប្រ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្តី ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោកអ៊ឹង ម៉េងស្រ៊ុន បានបង់នៅតុលាការកំពូលរួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់

ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យលោកយាក ឡុងខាង សងប្រាក់១៩.០០០៛ នេះទៅលោកអ៊ឹង ម៉េងស្រ៊ុន វិញ ។

៦-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៤ ។